**BMI0164**

## សម្ភាសន៍ជាមួយឈ្មោះ សូរ ឡាយ ភេទប្រុស អាយុ៩៧ឆ្នាំ

## មុខងារខ្មែរក្រហមៈ "នៅកងចល័ត"

## មានស្រុកកំណើតនៅភូមិពពាល ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## រស់នៅភូមិស្រះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០ៈ៣៣ៈ១៣

**១៥ទំព័រ**

វណ្ណៈ : អញ្ចឹងថ្ងៃហ្នឹងថ្ងៃទី១៧ ខែ០៦ ឆ្នាំ២០១១ ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ ម៉ោ ពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាពូណាស់ ហើយខ្ញុំម៉ោភូមិឃុំពូគឺផ្តោតទៅ លើរឿងរ៉ាវដែលទាក់ទងនឹង សម័យខ្មែរក្រហមពី៧៥ដល់៧៩ ជាពិសេសហ្នឹងគឺចង់ ដឹងរឿងរ៉ាវបងប្អូនយើងដែលបានធ្វើការនៅអាងត្រពាំងថ្ម តើជួបការលំបាកយ៉ាង ម៉េចខ្លះៗនៅក្នុងសម័យហ្នឹងពូណាស់?

ឡាយ : អ៊ូ!ពិបាកៗ ហួបបបរ ។

វណ្ណៈ : បាទ!អីចឹងបើសិនជាពូ ដឹងប៉ុនណា ពេលខ្ញុំសួរទៅពូអាចនិយាយប្រាប់ខ្ញុំតាមដំណើរការណ៍សាច់រឿងពូណាស់ តើការសម្ភាសន៍ខ្ញុំជាមួយពូ តើពូអនុញ្ញាតឲ្យក្មេងៗបាន ស្រាវជ្រាវប្ក៏យកទៅចងក្រងជាឯកសារ បានដឹងបានពូបានទេពូៗមិនថាអីទេប្រវត្តិសាស្រ្តហ្នឹង ដែលខ្ញុំនិយាយជាមួយពូហ្នឹង?

ឡាយ : បាទ!

វណ្ណៈ : ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូៗឈ្មោះអីដែរ?

ឡាយ : សូរ ឡាយ ។

វណ្ណៈ : ពូអាយុប៉ុន្មានហើយ?

ឡាយ : ខ្ញុំអាយុ៩៧ ។

វណ្ណៈ : ប្រពន្ធពូឈ្មោះអី?

ឡាយ : ប្រពន្ធខ្ញុំងាប់ហើយ ងាប់ចោលខ្ញុំហើយ ។

វណ្ណៈ : ឈ្មោះអីទៅ?

ឡាយ ៖ ឈ្មោះ ឈឹម សារ៉ុធ ស្លាប់ហើយស្លាប់បានមួយឆ្នាំហើយ ។

វណ្ណៈ ៖ គាត់ឈឺអីទៅ?

ឡាយ ៖ ដេក១ដល់ក្រោកឡើងឃើញគេដេកដីទៅ ងាប់បាត់ ។

វណ្ណៈ ៖ ចុះសល់កូនប៉ុន្មានដែលរាល់ថ្ងៃនេះ ទាំងអស់ប៉ុន្មាន?

ឡាយ ៖ កូនខ្ញុំតែ៤ទេប្រពន្ធមុន ទាំងអស់៥ចិញ្ចឹមកូនគេ១ កូនចិញ្ចឹម មានប្ដីហើយ ។

វណ្ណៈ ៖ អីចឹង៤នាក់ សព្វថ្ងៃការរួច២ នៅ២ទៀត?

ឡាយ ៖ បាទ!ការហើយ៣ហើយ ។

វណ្ណៈ ៖ ចុះឪពុករបស់ពូឈ្មោះអីទៅ?

ឡាយ ៖ ឪពុកខ្ញុំឈ្មោះ លឿង ។

វណ្ណៈ ៖ ត្រកូល?

ឡាយ ៖ មិនដឹងតាគាត់ឈ្មោះអីផង ។

វណ្ណៈ ៖ ម្ដាយ?

ឡាយ ៖ ម្ដាយឈ្មោះ គុយ មុន ។

វណ្ណៈ ៖ បាទ!សព្វថ្ងៃគាត់នៅរស់ដែរ?

ឡាយ ៖ នៅរស់ សព្វថ្ងៃគាត់ទៅវត្ត ។

វណ្ណៈ ៖ បាទ!បងប្អូនពូមានប៉ុន្មាននាក់?

ឡាយ ៖ បងប្អូនខ្ញុំមាន៧នាក់ ។

វណ្ណៈ ៖ នៅសល់ប៉ុន្មាន?

ឡាយ ៖ នៅសល់ទាំងអស់ ។

វណ្ណៈ ៖ ស្រុកកំណើតពូនៅណា?

ឡាយ ៖ នៅភូមិពាល ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ឥឡូវខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ៖ អ្ហូ!ពីមុនខេត្តបាត់ដំបង ឥឡូវខេត្តបន្ទាយមានជ័យ?

ឡាយ ៖ បាទ!

វណ្ណៈ ៖ ចុះកាលពីតូចពូបានរៀនដែរ?

ឡាយ ៖ ខ្ញុំបានរៀនដែរ តែភ្លេចអស់ហើយ រៀនតិច តែស៊ីឈ្នួលគេហ្នឹង ។

វណ្ណៈ ៖ អត់បានរៀនទេ?

ឡាយ : ហ្នឹងហើយ ដើរស៊ីឈ្នួលគេតាំងពីតូច រែកទឹកស្រោចថ្នាំ ស៊ីឈ្នួលគេ ។

វណ្ណៈ : អីចឹងកាលពីតូចៗអត់បានរៀនទេ ដើរស៊ីឈ្នួលគេ?

ឡាយ : ដើរស៊ីឈ្នួលគេ អត់បានរៀនទេ ។

វណ្ណៈ : ដើរស៊ីឈ្នួលដល់ឆ្នាំណាទៅ?

ឡាយ : ដល់ឆ្នាំ១៩៥៤ ។

វណ្ណៈ : ធំដឹងក្តីទៅដើរស៊ីឈ្នួលគេ ចុះដល់ធ្វើរដ្ឋប្រហារឆ្នាំ៧០អីពូដឹងទេ?

ឡាយ : ដឹង ។

វណ្ណៈ : ទម្លាក់សម្តេចសីហនុអីពូដឹងដែរ?

ឡាយ : បាទ!

វណ្ណៈ : ពេលហ្នឹងឆ្នាំ៧០អីសម័យសង្រ្គាមពូធ្វើអីដែរ?

ឡាយ : សម័យលន់ ណុលនោះ ។

វណ្ណៈ : បាទ! ពូធ្វើអីសម័យលន់ ណុល?

ឡាយ : អត់ធ្វើអីទេ!ខ្ញុំបួស ។

វណ្ណៈ : បួសបានប៉ុន្មានវស្សា?

ឡាយ : ខ្ញុំបួសបាន១វស្សា ។

វណ្ណៈ : ឆ្នាំណាបួស?

ឡាយ : ឆ្នាំ៧៤ ។

វណ្ណៈ : ឆ្នាំ៧៤បានបួសដែរ?

ឡាយ : បានបួស ។

វណ្ណៈ : ចុះសម័យសង្រ្គាមគេទម្លាក់គ្រាប់បែកហើយហ្នឹង?

ឡាយ : ដល់ឆ្នាំ៧៥ គេសឹកចោល ។

វណ្ណៈ : ឆ្នាំ៧៥ផ្សឹកចោល បើយើងអត់ផ្សឹកយ៉ាងម៉េចដែរ?

ឡាយ : បើគេបកសំពរយើង គេដេញយើងចេញហើយរស់ម៉េចបាន?

វណ្ណៈ : ចុះកាលពីសម័យពី៧០ដល់៧៤ហ្នឹង ពូដឹងថាមានហេតុការណ៍អីកើតឡើងទេនៅក្នុងភូមិហ្នឹង តាំងពី៧០-៧១-៧២-៧៣-៧៤អីអីចឹង?

ឡាយ : ៧៤ភូមិខ្ញុំនោះអត់មានទេ មានតែភូមិខ្ញុំនេះទេ ទម្លាក់គ្រាប់ភូមិនោះតាមព្រៃ ។

វណ្ណៈ : អញ្ចឹងពូបួសបាន១វស្សាពូបួសនៅវត្តណា?

ឡាយ ៖ ខ្ញុំបួសនៅវត្តបៀយស្វាយ បួសនៅវត្តនេះដដែរ ។

វណ្ណៈ ៖ វត្តណា?

ឡាយ ៖ ខ្ញុំបួសនៅវត្តនេះបាន១ខែកន្លះ ។

វណ្ណៈ ៖ បួសនៅវត្តបៀយស្វាយ ដល់៧៥ផ្សឹក?

ឡាយ ៖ បាទ!

វណ្ណៈ ៖ ផ្សឹក៧៥ហ្នឹង ខ្មែរក្រហមឲ្យពូធ្វើអី?

ឡាយ ៖ កាលនោះមានអីចល័ត ។

វណ្ណៈ ៖ ចល័តស្រុក ឬក៏ចល័តតំបន់?

ឡាយ ៖ មុនដំបូងចល័តឃុំ ដល់ខ្ញុំចូលបានមួយឆ្នាំបានខ្ញុំចូលដល់ចល័តតំបន់ ។

វណ្ណៈ ៖ បាន១ឆ្នាំចល័តតំបន់ កាលពូនៅចល័តឃុំហ្នឹងចល័តឃុំគេឲ្យធ្វើអីខ្លះ?

ឡាយ ៖ គេឲ្យលើកភ្លឺ ស្ទូង ។

វណ្ណៈ ៖ កាលហ្នឹងពូមានតួនាទីអីខ្លះដែរ កាលនៅឃុំហ្នឹង?

ឡាយ ៖ អត់មានទេ ខ្ញុំគ្រាន់តែលើកទំនប់ លើកប្រឡាយប៉ុននោះឯង ។

វណ្ណៈ ៖ បើអីចឹងពីណាប្រធានពូទៅ?

ឡាយ ៖ ប្រធានគាត់ស្លាប់បាត់ហើយ ។

វណ្ណៈ ៖ ពីណាគេ?

ឡាយ ៖ ប្រធានខ្ញុំនោះគាត់នៅ ភ្លេចបាត់ហើយ ភ្លេចឈ្មោះប្រធាន ។

វណ្ណៈ ៖ អីចឹងកាលហ្នឹងពូស្គាល់គណៈភូមិភាគ គណៈតំបន់ គណៈអី ពូស្គាល់ទេ?

ឡាយ ៖ គណៈតំបន់មានតា ខាងទំនប់នោះខាង តាលឹម ហើយខាងនេះតាសំអាត ។

វណ្ណៈ ៖ ខាងណាតាសំអាត?

ឡាយ ៖ តាសំអាត ខាងភូមិភាគពាយ័ព្យនេះឯង គេហៅតាជន្គង់ក្រហម ។

វណ្ណៈ ៖ តាសំអាត ហៅតាជន្គង់ក្រហម ។

ឡាយ ៖ បាទ!

វណ្ណៈ ៖ ឈ្មោះគាត់ពីរ?

ឡាយ ៖ ឈ្មោះគាត់អ្នកនិរតី ដល់និរតីម៉ោហៅគាត់តែតាជន្គង់ក្រហម ។

វណ្ណៈ ៖ ចុះពូស្គាល់តាជៀល ស្គាល់តាហ៊ីង ស្គាល់តាវ៉ាល់ អីទេកាលហ្នឹង?

ឡាយ ៖ តាជៀល ស្គាល់ តាវ៉ាល់ស្គាល់ ។

វណ្ណៈ : ចុះតាជៀល គាត់ធ្វើអី តាជាល?

ឡាយ : តាជៀល ធ្វើខាងគណៈស្រុកដែរ តាសំអាតក៏គណៈស្រុកដែរ ។

វណ្ណៈ : គាត់កាន់ខាងផ្នែកអីពូមានដឹងទេ?

ឡាយ : ខ្ញុំក៏មិនយល់ដែរ ព្រោះខ្ញុំចល័តស្រុកកាលហ្នឹង ។

វណ្ណៈ : ចុះពូកាលហ្នឹងគណៈភូមិភាគអីពូស្គាល់ទេ មានដែលឮឈ្មោះអីប្អូអត់?

ឡាយ : ភូមិភាគហ្នឹង មានអីមានតែភូមិភាគពាយ័ព្យយើងហ្នឹង ហើយនិរតីតាជឹម ។

វណ្ណៈ : ពាយ័ព្យមានពីណាខ្លះ?

ឡាយ : ពាយ័ព្យគេយកទៅវៃចោលអស់ ។

វណ្ណៈ : វៃចោលអស់ហ្នឹងឈ្មោះអីទៅ?

ឡាយ : ឈ្មោះ ។

វណ្ណៈ : ចុះតា ញឹម អីដែលឮឈ្មោះទេ?

ឡាយ : តាញឹម ឮ តាញឹមដែលគាត់នៅខាងនោះឯង សុទ្ធតែអ្នកធំៗណាស់ ។

វណ្ណៈ : ចុះពូបន្ទាប់ពីចល័តភូមិហើយ ពូទៅចល័តតំបន់ហ្នឹង ទៅអាងត្រពាំងថ្មតែម្ដងប្អូក៏ទៅកន្លែងណាសិន?

ឡាយ : ខ្ញុំចូលត្រពាំងថ្ម ។

វណ្ណៈ : នៅឆ្នាំណាទៅត្រពាំងថ្ម?

ឡាយ : ឆ្នាំ៧៦ ឲ្យជណ្ដើរ ដល់លីវែកទៅធ្វើកាំជណ្ដើរដាក់ឡើង បើយើងមិនឡើង គេវៃយើងចោល ។

វណ្ណៈ : អីចឹងខ្ញុំចង់សួរពូដំបូងដែរ ទៅដល់អាងត្រពាំងថ្មដំបូងគេឲ្យពូធ្វើអីខ្លះ គេមានបែងចែកជាម៉ែត្រគីប ឬក៏ធ្វើអីខ្លះដែរខ្លះទៅពូ?

ឡាយ : ម៉ែត្រគីប ២ម៉ែត្រគីប១ម្នាក់ ។

វណ្ណៈ : ចុះមានបែកចែកកម្លាំងប្រុសស្រីទី១ ទី២ ទី៣ដែរ?

ឡាយ : មាន ក្នុងមាក្រុមខ្ញុំមានគ្នា៨០នាក់ ។

វណ្ណៈ : ៨០នាក់?

ឡាយ : បាទ!មាក្រុមខ្ញុំ មាកងខ្ញុំ តែខ្ញុំមិនដឹងថាប្រុសប៉ុន្មាន ស្រីប៉ុន្មានខ្ញុំអត់បានចាំទេ ។

វណ្ណៈ : ឥឡូវខ្ញុំសួរដូចថា ម្នាក់២ម៉ែត្រគីបហ្នឹងបើយើងមិនហើយ ម៉េចដែរ?

ឡាយ : យើងមិនហើយគេវៃយើងចោលប៉ុននោះឯង ។

វណ្ណៈ : ហ៊ឺ!ដល់ថ្នាក់វ៉ៃចោលទៀត?

ឡាយ : បាទ!

វណ្ណៈ : មិនមែនត្រឹមបង្អត់បាយទេ?

ឡាយ : អេ៎!វ៉ៃចោល គ្រាន់តែឆ្លូតទឹកៗស្រីៗគ្នាឆ្លូត ស្មៀកស្មើងចេះផ្លាស់ហ្នឹងអត់បានទេ យកវ៉ៃចោលដែរ ។

វណ្ណៈ : ចុះកាលហ្នឹងហូបចុកយ៉ាំងម៉េចដែរ?

ឡាយ : បបរ ។

វណ្ណៈ : ចុះទឹកអីហូបគ្រប់គ្រាន់ទេ?

ឡាយ : ទឹកនោះបានហូបគ្រប់គ្រាន់ បានតែបបរប៉ុននោះឯង ។

វណ្ណៈ : ចុះនៅក្រុមពូ៨០នាក់ហ្នឹង ពីណាប្រធាន?

ឡាយ : ឈ្មោះអីទេខ្ញុំភ្លេចហើយ ។

វណ្ណៈ : ភ្លេចហើយពូអត់ចាំទេ?

ឡាយ : អត់ចាំទេ ។

វណ្ណៈ : ពូគិតមើលថានៅអាងត្រពាំងថ្មហ្នឹងមានមនុស្សប្រហែលប៉ុន្មាននាក់ទៅ?

ឡាយ : អ៊ូ!ច្រើន គ្រាន់តែខ្ញុំសួរពេទ្យ គ្រាន់តែគេវ៉ៃចោលហើយនឹងស្លាប់នឹងពេទ្យនោះអស់ ៤៤នាក់ ខ្ញុំសួរពេទ្យ ទាំងវ៉ៃចោល ទាំងស្លាប់នឹងពេទ្យស្លាប់អស់៤៤នាក់ ។

វណ្ណៈ : ស្លាប់ហ្នឹងស្លាប់យ៉ាំងម៉េច?

ឡាយ : អត់បាយអត់ទឹកក៏ស៊ីមិនគ្រប់គ្រាន់ទៅ ហើយគ្រាន់តែស្លាប់ដែលគេវ៉ៃចោលនោះមិន ដឹងប៉ុន្មាននាក់ទេ គ្រាន់តែសួរពេទ្យ ពេទ្យថាអស់៤៤នាក់ ។

វណ្ណៈ : ម៉េចបានពូហ៊ានសួរពេទ្យ?

ឡាយ : ចុះពេទ្យហ្នឹងត្រូវជាបងជីដូនមួយខ្ញុំហ្នឹងឯង ។

វណ្ណៈ : បាទ!ចុះពូដូចថា នៅហ្នឹងមានដូចថា គេធ្វើរោងឲ្យយើងដេក មានគ្រែមានអីគ្រប់គ្រាន់ ឲ្យយើងដេកដែរឬមិនមានទេ?

ឡាយ : អត់មានគ្រែទេ គេធ្វើតែរោងប៉ុននោះឯង អត់មានគ្រែមានអីទេ ដេកនឹងដី ។

វណ្ណៈ : បាទ!ហើយនៅហ្នឹងយើងមានសម្ភារៈអីខ្លះ សម្រាប់ម្នាក់ៗ?

ឡាយ : មានស្ពឺ មានតែចប បង្គី២ ដងរែកមួយ ។

វណ្ណៈ : អីចឹងសម្ភារៈសម្រាប់ម្នាក់ៗ?

ឡាយ : ហ្នឹងហើយម្នាក់ៗ ។

វណ្ណៈ : ហើយបើពូទៅបានឃើញអាងត្រពាំងថ្មហ្នឹង តើអាងហ្នឹងដូចថាមានកម្ពស់ប៉ុន្មានហើយ ទឹងទទឹងខ្ពង់លើប៉ុន្មាន ហើយបណ្ដោយប្រហែលជាប៉ុន្មានដែរពូ?

ឡាយ : ខ្ញុំដូចជាភ្លេចហើយ គ្រាន់តែមើលអាងកូនខ្វែងហ្នឹង មើលទៅដូចម៉ាកញ្ចប់ អាងធំណាស់ ។

វណ្ណៈ : ធំណាស់ ហើយមនុស្សប្រហែលជាប៉ុន្មាន ពូអាចស្មានអាចនិយាយបានទេ?

ឡាយ : អ៊ូ!រាប់ពាន់នាក់ៗ ចុះគ្រប់ភូមិ ម្នាក់ ។

វណ្ណៈ : គ្រប់ស្រុកឬគ្រប់ភូមិ?

ឡាយ : គ្រប់ស្រុក គ្រប់ភូមិ ។

វណ្ណៈ : ហើយចេះទៀតខ្ញុំចង់ដឹងថា កាលពូនៅអាងត្រពាំងថ្មហ្នឹង មានអ្នកធំណាខ្លះដែលទៅមើលទៅអីដែរ?

ឡាយ : អ៊ូ!ខ្ញុំមិនដឹងថាអ្នកណាធំ អ្នកណាតូចទេខ្ញុំ ។

វណ្ណៈ : ពូអត់ដឹងទេ?

ឡាយ : អត់ដឹងទេ ។

វណ្ណៈ : ហើយចុះដែលពូគាវ៉ាល់ អីទៅមើលទេ?

ឡាយ : គាវ៉ាល់ មិនដែលទៅទេ នេះទំនប់គាវ៉ាល់ហើយ ពីកំបោរនេះទំនប់គាវ៉ាល់ ហើយ ។

វណ្ណៈ : ដើមគរពាដើមនេះ?

ឡាយ : នេះអាទំនប់ពីកំបោរនេះ ទំនប់គាវ៉ាល់ហើយ ។

វណ្ណៈ : អញ្ចឹង ចុះអាងត្រពាំងថ្មទំនប់ពីណាវិញ?

ឡាយ : មិនដឹងពីណាទេ ខ្ញុំអត់ដឹងទេ គ្រាន់តែលើកគេឲ្យទៅលើកក៏លើក ។

វណ្ណៈ : ចុះក្រុមពូ៨០នាក់ហ្នឹង មានស្លាប់ដោយសារអត់អាហារ អត់បាយអីដែរ?

ឡាយ : ក្រុមខ្ញុំគេវ៉ៃចោលអស់២នាក់ស្រី ។

វណ្ណៈ : អីចឹង ឈ្មោះអីខ្លះ?

ឡាយ : មិនដឹងឈ្មោះអីទេ ស្រី គេវ៉ៃគេថាគាត់រិះគន់ គាត់ច្រៀងចំរៀង«សេកមាស» ។

វណ្ណៈ : គេវ៉ៃចោល?

ឡាយ : វ៉ៃចោល ។

វណ្ណៈ : កងនារី ហើយកងបុរសគេដាក់ឲ្យនៅខុសគ្នា ឬឲ្យនៅជាមួយគ្នា?

ឡាយ ៖ ខុសគ្នា ពេលគេផ្សេង តែប្រុសៗដូគ្នាឯង ដល់ធ្វើការផ្សេងគ្នា ។

វណ្ណៈ ៖ ចុះចំពោះពូវិញវែក១ថ្ងៃ២ម៉ែត្ររាល់ថ្ងៃ?

ឡាយ ៖ រាល់ថ្ងៃ ។

វណ្ណៈ ៖ ចុះពូដែលលើកមិនទាន់ដែនការណ៍របស់ថ្នាក់លើកបុអត់?

ឡាយ ៖ អ៊ូ!ខ្ញុំលើកសុទ្ធតែ១ម៉ោង២បន្តីនោះវែក បើមិនអីចឹងមិនរួច ។

វណ្ណៈ ៖ វែកហ្នឹងប្រហែលរយៈពេលបានប៉ុន្មាន១ឆ្នាំទេ?

ឡាយ ៖ វែកហ្នឹងជាង១ខែ ។

វណ្ណៈ ៖ ម៉េចវែកបានតិចម្ល៉េះ?

ឡាយ ៖ លើកទំនប់បានមាំខែហ្នឹងហើយរួច ។

វណ្ណៈ ៖ មិនមែនទេពូ ព្រោះទំនប់ហ្នឹងវាធំណាស់ រាប់គីឡូនោះតាមខ្ញុំដឹង អីចឹងត្រូវចំណាយមនុស្សលើកច្រើនណាស់ ។

ឡាយ ៖ អេ៎!ទំនប់ហ្នឹងវាចាស់ពីដើម យើងលើកបំពេញៗ ទំនប់ខ្ពស់ដូចអាក្បែរលូ ក្បែរស្ពានខ្ពស់នោះឯង បើទៅលិចនោះគ្រាន់តែបំមពេញទេ ។

វណ្ណៈ ៖ ចុះពូថាទំនប់ហ្នឹងដល់ដាក់ជណ្ដើរវែកឡើងនោះ មានន័យថាវាខ្ពស់វាធំហើយ?

ឡាយ ៖ ខ្ពស់ ។

វណ្ណៈ ៖ ចុះមាន មនុស្សធ្លាក់ដោយសារដាក់ជណ្ដើរ ដាក់អីធ្លាក់ម៉ោវិញអីចឹងដែរ?

ឡាយ ៖ ទេ!អត់មានទេ អត់មានធ្លាក់ទេ ។

វណ្ណៈ ៖ នៅក្នុងសម័យហ្នឹង ពូអត់ស្គាល់មេដឹកនាំណាច្បាស់លាស់ដែរ?

ឡាយ ៖ អ៊ូ!ខ្ញុំអត់ច្បាស់លាស់ដែរ ។

វណ្ណៈ ៖ ចុះពូដឹងថាពួកនិរតីចូលម៉ោពូមានដឹងទេ ចូលម៉ោចាប់ពួកតាក្រុក ចាប់តាវ៉ាល់អីពូមានដឹងទេកាលហ្នឹង?

ឡាយ ៖ យាយកាលហ្នឹងចាប់ តាក្រុក ខ្ញុំរត់ទៅនៅស្មាច់៩នាក់ ។

វណ្ណៈ ៖ ម៉េចបានរត់ពូ?

ឡាយ ៖ ចុះគេរកចាប់ខ្ញុំនោះ ។

វណ្ណៈ ៖ ម៉េចបានគេរកចាប់ពូ?

ឡាយ ៖ គេដកខ្ញុំទៅបង់ក៏ ខ្ញុំឲ្យសំណាញ់គេ ។

វណ្ណៈ ៖ អីចឹង!ពូបានសំណាញ់ពីណាទៅបង់ ព្រោះសម័យហ្នឹងវាតឹងរឹងដែរ?

ឡាយ : សំណាញ់មាន ដល់ខ្ញុំឲ្យសំណាញ់គេរាយការណ៍ទៅកន្លែងឃុំ ថាឲ្យម៉ោចាប់ខ្ញុំ៩នាក់ ។ ៩នាក់ខ្ញុំរត់ៗមុខព្រៃស្មាច់ ។

វណ្ណៈ : ព្រៃស្មាច់នៅខាងណាវិញទៅ?

ឡាយ : ព្រៃស្មាច់នៅយើងទៅនៅព្រៃហ្នឹង ។

វណ្ណៈ : ទៅនៅព្រៃរហូត?

ឡាយ : ទៅនៅព្រៃបាន គិតទៅមនុស្សមុនដំបូង៨នាក់ទេ ដល់យូរៗទៅបាន៧០០នាក់ ។

វណ្ណៈ : ៧០០នាក់?

ឡាយ : បាទ!៧០០នាក់បានចាញ់និរតីម៉ោ គេហៅម៉ោវិញៗដល់អីចឹងគេបញ្ជូនទៅនៅ ទឹកជោរនេះ ។

វណ្ណៈ : អីចឹងជំនាន់តាក្រក តាវ៉ាល់ អីហ្នឹងក៏មានសម្លាប់មនុស្សដែរ?

ឡាយ : អ្ហូ!ម៉ាជំនាន់ហ្នឹងមិនសូវសម្លាប់ទេ សម្លាប់តែសម័យខាងនិរតីចូលម៉ោ ។

វណ្ណៈ : ឆ្នាំណាពូហ្នឹងថាពួកនិរតីចូលម៉ោ?

ឡាយ : និរតីចូលឆ្នាំ៧៣-៧៤មិនដឹង ។

វណ្ណៈ : អត់ទេពូ ៧៣-៧៤ខ្មែរក្រហមអត់ទាន់ចូលផងពូ អត់ទេ!សម័យ៧២នេះទឹមសម័យតស៊ូជាមួយលន់ ណុលនៅឡើយទេ ខ្ញុំចង់និយាយពី៧៥ដល់៧៩ អីចឹងពីចន្លោះ៧៥ដល់៧៩ពូទៅរែកទំនប់នៅអាងត្រពាំងថ្ម តាំងពី៧៧នោះហ្នឹង អញ្ចឹងនិរតីចូលម៉ោ៧៨អីហ្នឹង តែពូអត់បានដឹង ពូមិនសូវចាំឆ្នាំអីចឹង?

ឡាយ : បាទ!

វណ្ណៈ : ខាងនិរតីចូលម៉ោហ្នឹង គឺខាងវៀតណាមជិតចូលម៉ោដែរហើយ អីចឹងពួកនិរតីចូលម៉ោចាប់មនុស្សសម្លាប់បន្ថែមទៀត ។ អីចឹងពួកនិរតីចូលម៉ោ ពូថាហៅគ្នាពូចេញពីព្រៃម៉ោគ្នាប៉ុន្មាន៦-៧០០នាក់យ៉ាំងម៉េច?

ឡាយ : ៧០០នាក់ចេញពីព្រៃ ។

វណ្ណៈ : ម៉េចរត់ចូលព្រៃដំបូងឡើយ?

ឡាយ : ចុះគេដេញចាប់នោះ គេចាប់មិនរត់ចូលព្រៃមិន (សើច) ។

វណ្ណៈ : ដល់ខាងនិរតីគេហៅម៉ោវិញគេធ្វើបាបយើងឬអត់?

ឡាយ : អត់មានទេ!អត់មានធ្វើបាបទេ ។

វណ្ណៈ : ម៉ោឲ្យធ្វើការធម្មតា?

ឡាយ ៖ ធ្វើការធម្មតា បានប្រហែល១ខែផង បានឃួនចូលម៉ោហ្នឹង ។

វណ្ណៈ ៖ អញ្ចឹងធ្វើទំនប់អាងត្រពាំងថ្មហើយ កាលហ្នឹងពូរៀបរាប់មើល៉ តើវា?

ឡាយ ៖ ខ្ញុំធ្វើអាងត្រពាំងថ្មរួច ខ្ញុំម៉ោនៅគរ៣ដើម ដល់គរ៣ដើម ទេ!ធ្វើនេះសិនអាទំនប់ យើងក្បែរភ្នំសារ ធ្វើរួចបានខ្ញុំគេឲ្យជញ្ជូនទៅនៅដើមគរ៣ដើម ។

វណ្ណៈ ៖ អាហ្នឹងក៏គ្នាច្រើនដែរ?

ឡាយ ៖ អ្ហូ!គ្នាច្រើនណាស់ ។

វណ្ណៈ ៖ ចុះអ្នក១៧ ពួកថ្មី គេហៅថាប្រជាជនថ្មីម៉ោពីភ្នំពេញហ្នឹង តើម៉ោកន្លែងទំនប់ តាមភូមិអីមានស្លាប់ច្រើនទេ?

ឡាយ ៖ អ្ហូ!ស្លាប់ទៅស្លាប់ច្រើនដែរ ពីអាងត្រពាំងថ្មម៉ោដល់នេះហ្នឹង ខ្ញុំសួរពេទ្យហើយឆាប់ អស់ទាំងវ៉ើ ទាំងដេកពេទ្យអស់៤៨នាក់ ។

វណ្ណៈ ៖ តែប៉ុនហ្នឹងទេ?

ឡាយ ៖ បាទ! ហើយបានគេដកខ្ញុំពីនោះម៉ោ គេបញ្ជូនខ្ញុំទៅខាងនោះស្វាយ ទៅច្រូតនោះ ។

វណ្ណៈ ៖ អីចឹងបុរសៗច្រូតដែរ?

ឡាយ ៖ ច្រូត ។

វណ្ណៈ ៖ អត់មានទៅភ្ជួរអីទេ?

ឡាយ ៖ ទេ ។

វណ្ណៈ ៖ កាលសម័យខ្មែរក្រហមពូយកគ្រួសារឬនៅ?

ឡាយ ៖ កាលសម័យខ្មែរក្រហមមានហើយ ។

វណ្ណៈ ៖ មាននៅឆ្នាំណា?

ឡាយ ៖ ក្រោមប្រពន្ធទី១នោះ បានជាឆ្នាំ៧៣ ។

វណ្ណៈ ៖ ការមុនខ្មែរក្រហមទៀត?

ឡាយ ៖ បាទ!

វណ្ណៈ ៖ ពូថា៧៤ពូបួសហ្នឹងបានប្រពន្ធម៉េចកើត?

ឡាយ ៖ ៧៣ខ្ញុំផ្សឹកវិញ ។

វណ្ណៈ ៖ ពូថា៧៤ចូលបួស ហើយ៧៥ខ្មែរក្រហមចូលផ្សឹកពូ ពូគិតមើលម្តងទៀតមើល?

ឡាយ ៖ ទេ!ខ្ញុំផ្សឹក៧៣ ដែលខ្ញុំបួសហ្នឹង៧៣ ។

វណ្ណៈ ៖ បាទ!ហើយផ្សឹកវិញ?

ឡាយ : ផ្សឹកវិញ៧៤ ខ្ញុំបានប្រពន្ធខ្ញុំនោះ៧៦ ។

វណ្ណៈ : អ៊ូ!ចូលខ្មែរក្រហមហើយ ខ្មែរក្រហមរៀបឲ្យអីចឹង?

ឡាយ : បាទ! ៧៦ ដល់ប្រពន្ធខ្ញុំស្លាប់ ខ្ញុំបាននេះឆ្នាំ៨៣ ។

វណ្ណៈ : អីចឹងការសម័យខ្មែរក្រហម?

ឡាយ : ប្រពន្ធសព្វថ្ងៃនេះស្លាប់ទៀត ។

វណ្ណៈ : អីចឹង ឥឡូវនៅកម្មោះដដែល?

ឡាយ : ចុះបើគេស្លាប់ចោលយើងហើយ?

វណ្ណៈ : ចុះពូកាលឆ្នាំហ្នឹងពូ ៧៦ថាមានប្រពន្ធអីចឹង មានអ្នកមានប្រពន្ធគេបញ្ជូនទៅលើកទំនប់នៅអាងត្រពាំងថ្មដែរ?

ឡាយ : នៅបែកគ្នា ។

វណ្ណៈ : អញ្ចឹងកាលហ្នឹងពូអត់ទាន់មានកូនទេ អីយ៉ាងម៉េច?

ឡាយ : បានកូនមួយ ។

វណ្ណៈ : អញ្ចឹងកូនហ្នឹងយកទៅណាទៅ?

ឡាយ : កូនហ្នឹងស្លាប់ដដែល កូនប្រុស ។

វណ្ណៈ : ពូចង់ឲ្យពូនិយាយលំអិតកន្លែងអាងត្រពាំងថ្ម តើពូឃើញសភាពយ៉ាងម៉េចខ្លះនៅពេលហ្នឹង?

ឡាយ : អ៊ូ!អាងត្រពាំងថ្មទេសភាពល្អណាស់ៗ ឡើងលើទំនប់ទៅមើលអាភ្នំកូនខ្លែង មើល ទៅ ។

វណ្ណៈ : ខ្ញុំចង់ឲ្យនិយាយពីសកម្មភាពមនុស្ស នៅកន្លែងហ្នឹងដូចថាវាលំបាកយ៉ាងម៉េចអីយ៉ាងម៉េច?

ឡាយ : អ៊ូ!វាវេទនាហ្នឹង ហូបបាយ ផឹកទឹកអត់មានកន្សែងក្រាស់ៗបេះដូចសព្វថ្ងៃនេះណាកន្សែងស្តើងៗ ហើយអណ្តូងជីកអណ្តូងតែយើង បើមនុស្សប្រុសមិនសូវអីទេ បើមនុស្សស្រីគ្នាផ្លាស់ចុះមានសំពត់ណា គ្នាផ្លាស់កន្សែងទៅ ក៏ស្តើងទៅក៏យកគ្នាទៅវ៉ៃចោលដែរនោះ អ៊ូ!ខ្ញុំវេទនាណាស់ កម្មឡើងស្រកទឹកភ្នែក ។

វណ្ណៈ : ពូអត់ដែលគេធ្វើបាបអីទេពូ?

ឡាយ : ខ្ញុំហ្នឹង?

វណ្ណៈ : បាទ!?

ឡាយ :　ទេ!កាលហ្នឹងខ្ញុំម៉ោពីជប៉ុនៗ ម៉ោដេកភ្នំពេញបាន៣យប់ៗ គេម៉ោតាមអូសរទេះសេះឲ្យខ្ញុំទៅភូមិត្រយ៉ូង ខ្ញុំថាខ្ញុំអត់ទៅទេៗ កុំបានបងថ្លៃខ្ញុំនេះៗជួយ កុំតែបានបងថ្លៃខ្ញុំជួយខ្ញុំងាប់បាត់ទៅហើយ ចុះអូសដាក់រទេះសេះហើយ ដែលរស់ ។

វណ្ណៈ :　ម៉េចបានអូសរទេះសេះ?

ឡាយ :　គេដាក់ទៅត្រយ៉ូង ។

វណ្ណៈ :　ត្រយ៉ូងគេទៅធ្វើអី?

ឡាយ :　គ្រូ គេសុទ្ធតែដាក់ខ្នោះ ។

វណ្ណៈ :　គេធ្លាប់ដាក់ខ្នោះពូដែរ?

ឡាយ :　ខ្ញុំរត់ម៉ោពីជប៉ុន នេះឈើប្រកអាគេដាក់ខ្នោះជើង ខ្នោះដៃ ។

វណ្ណៈ :　ចុះពូធ្លាប់ជាប់ដែរ?

ឡាយ :　ទេ!អត់ធ្លាប់ជាប់ទេ ។

វណ្ណៈ :　ពីណាធ្លាប់ជាប់?

ឡាយ :　អ៊ូ!មិនដឹងពីណាពីណីទេ ។

វណ្ណៈ :　ចុះនៅក្នុងតំបន់របស់ពូហ្នឹងតំបន់ប៉ុន្មាន ដែលពូរស់នៅកាលហ្នឹង?

ឡាយ :　តំបន់៥ ។

វណ្ណៈ :　ចុះនៅតំបន់៥ហ្នឹង ពូដឹងថាកន្លែងណាមានមន្ទីរគុក សន្តិសុខអីដែរ?

ឡាយ :　ទេ! មានតែខ្នាច ម៉ាកន្លែងៗយើងចូល ។

វណ្ណៈ :　ខ្នាចនៅខាងណាវិញ ព្រះនេត្រព្រះហ្នឹងដែរ?

ឡាយ :　ខ្នាច ក្បែររហាលនេះ វត្តបាត់គងនេះ ។

វណ្ណៈ :　វត្តបាក់គង?

ឡាយ :　បាទ! ខ្នាច ខាងជើងស្វាយឆេះ ។

វណ្ណៈ :　មានមន្ទីរសន្តិសុខ?

ឡាយ :　មានកន្លែងឈ្លបមួយហ្នឹងឯង មានកន្លែងវ៉ៃចោល មានដាក់អង្រែ១ ត្បាល់១ បានយួនចូលមកក៏បានចាស់ៗគាស់ដុត ។

វណ្ណៈ :　គាស់?

ឡាយ :　គាស់ដុត តាៗ... ។

វណ្ណៈ :　ពូដឹងក្រោយ៧៩ហើយ?

ឡាយ : ៧៩ ។

វណ្ណៈ : បាទ!អញ្ចឹងពូបានទៅគាស់សាកសពអ្នកទាំងអស់ហ្នឹងទេ?

ឡាយ : ទេ!ខ្ញុំអត់បានគាស់ទេ គាៗអ្នកគាស់ៗជុត ជុតស្រះប៉ុនណាណីនោះ ។

វណ្ណៈ : បាទ! ចុះពូដឹងថាអ្នក១៧មេសា ហើយនឹងអ្នកប្រជាជនមូលដ្ឋានហ្នឹង តើអ្នកណាស្លាប់ច្រើនជាង បើតាមពូដឹង?

ឡាយ : អត់ដឹងទេ ។

វណ្ណៈ : ចុះពេលវៀតណាមម៉ោ បែក៧៩ហ្នឹងពួកនិរតីហ្នឹងរត់ទៅខាងណាពូមានដឹងទេ?

ឡាយ : រត់ទៅលើកនោះ..... ។

វណ្ណៈ : បាទ!កាលហ្នឹងដែរ ខ្ញុំចង់សួរកាលពួកនិរតីចូលម៉ោហ្នឹង ពូអត់ស្គាល់អ្នកធំណាខ្លះទេ?

ឡាយ : ទេខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ : ចុះយាយថែម អីស្គាល់ទេ?

ឡាយ : យាយថែម ស្គាល់ យាយថែម ហើយយាយកាដុំស័ក្ត ។

វណ្ណៈ : កាដុំស័ក្តមួយណាទៅ?

ឡាយ : គាត់ដោះតែម៉ាចំហៀងទេ យាយហ្នឹង មានដោះតែមួយចំហៀងទេ ។

វណ្ណៈ : ម៉ោពីខាងណាយាយកាដុំស័ក្តហ្នឹង?

ឡាយ : នៅលើនោះឯង ។

វណ្ណៈ : នៅលើណាទៅ?

ឡាយ : នៅលើនេះ គេហៅភូមិតាដួលៗនោះ ។

វណ្ណៈ : ក្នុងសម័យខ្មែរក្រហម?

ឡាយ : ហ្នឹងហើយរត់ទៅ ។

វណ្ណៈ : អូ!យាយកាដុំស័ក្តក្រោយទេ?

ឡាយ : បាទ!

វណ្ណៈ : ហើយចុះយាយថែម ខ្ញុំសួរយាយថែម?

ឡាយ : យាយថែម កើតសម័យ ។

វណ្ណៈ : ខ្មែរក្រហមមានស្គាល់គាត់ទេ ធ្លាប់ជួបគាត់ ធ្លាប់និយាយភាសាអីជាមួយគាត់ទេ?

ឡាយ : ទេ!កាលខ្ញុំទៅយកគោៗ ដឹកគោទៅ ទៅជួបគាត់នៅគេហៅវត្ត ក្បែរផ្សារនោះ អែបឯស្ពានដែក ខាងលិចផ្សារនោះ គាត់ថា ពូម៉ោពីណា? ខ្ញុំម៉ោពីដឹងគោ ។

វណ្ណៈ : គាត់ជិះអីយាយចែម ?

ឡាយ : គ្មានជិះអីគាត់ឈរនៅលើភ្នំ ។

វណ្ណៈ : ភ្នំកន្លែងណាទៅ?

ឡាយ : អាភ្នំខាងត្បូងវត្តពីផ្សារយើងនេះ សព្វថ្ងៃរលាយហើយវត្តនោះ ។

វណ្ណៈ : មិនមែននៅឈរកន្លែងអាងត្រពាំងថ្មទេ?

ឡាយ : ទេ!មិនមែនទេ ។

វណ្ណៈ : អីចឹងក្រោយ៧៩ ដែលវៀតណាមចូលម៉ោហ្នឹង ខាងនិរតីគេរត់អស់ហើយ?

ឡាយ : រត់ ។

វណ្ណៈ : រត់ ចុះពូរត់ទៅខាងណាវិញដែរ?

ឡាយ : ខ្ញុំអត់រត់ទេ ។

វណ្ណៈ : ម៉ោស្រុកកំណើត?

ឡាយ : បាទ! ចុះខ្ញុំភូមិនៅនោះ ។

វណ្ណៈ : បាទ!ម៉ោស្រុកកំណើតវិញ មកដល់រាល់ថ្ងៃហ្នឹងពូធ្វើការអីដែររាល់ថ្ងៃ?

ឡាយ : គ្មានធ្វើការអី ធ្វើស្រែហ្នឹង ។

វណ្ណៈ : ក្រោយ៧៩នៅកន្លែងភូមិឃុំពូហ្នឹង មានខ្មែរក្រហមធ្វើឲ្យរំខាន ការងាររកស៊ីធ្វើស្រែចំការអីដែរឬអត់ ក្រោយ៧៩?

ឡាយ : អ៊ូ!អត់មានទេ ។

វណ្ណៈ : អត់ទេ!អញ្ចឹងនៅកន្លែងហ្នឹងមានវៀតណាម មានអី?

ឡាយ : មាន ។

វណ្ណៈ : អញ្ចឹងពូខ្ញុំចង់សួរពូបន្តិចទៀតដែលទាក់ទងម៉ោ កន្លងមៅពូមានដែលស្តាប់រឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអីដែរ?

ឡាយ : ទេ!អត់ដែលព្ទទេ ។

វណ្ណៈ : អត់ដែលព្ទទេ?

ឡាយ : អត់ដែលព្ទទេ ។

វណ្ណៈ : ចុះពូអត់ដឹងថាមានការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ឡាយ : ទេ ។

វណ្ណៈ ៈ អញ្ចឹងពូរាល់ថ្ងៃនេះគេធ្វើការកាត់ទោសរយៈពេលជាច្រើនឆ្នាំម៉ោរឿងករណីឌុច ប៉ុន្តែថ្មីៗនេះ ឆ្នាំនេះគេនឹងកាត់ទោសតាអៀង សារី តានួន ជា តាខៀវ សំផន ប្រពន្ធអៀង សារី ។

ឡាយ ៈ កាត់ទោសតាម៉ុក មុនដំបូង?

វណ្ណៈ ៈ ហ្នឹងហើយ តាម៉ុក គាត់មិនមែននៅក្នុងតុលាការអន្តរជាតិទេ តារដ្ឋាភិបាលចាប់ទេ?

ឡាយ ៈ បាទ!

វណ្ណៈ ៈ តែគាត់ស្លាប់ហើយ ប៉ុន្តែថ្មីៗនេះគេចាប់នៅសល់តែ ខៀវ សំផន អីអីចឹង។ អីចឹងពូគិតថាការកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹង ជាការត្រឹមត្រូវឬមិនត្រឹមត្រូវទេ បើយោបល់របស់ពូ?

ឡាយ ៈ ខ្ញុំមិនដឹងដែរ ខ្ញុំអត់ដឹងទេ។

វណ្ណៈ ៈ ចេះ កាលហ្នឹងខ្មែរក្រហមគាត់កាន់កាប់រយៈពេល៣ឆ្នាំជាងហ្នឹង ធ្វើឲ្យមានការបាត់បង់ជីវិតមនុស្សអស់ជាង១លាននាក់ពូណាស់ ដល់ពេលឥឡូវអន្តរជាតិនឹងតុលាការខ្មែរយើងហ្នឹងចូលរួមគ្នា ដើម្បីធ្វើការកាត់សេចក្ដីទៅលើ បទល្មើសដែលគាត់បានរំលោភមកលើសិទ្ធិមនុស្សអី នៅក្នុងសម័យខ្មែរក្រហមអីចឹង។ អីចឹងពូថាយកអ្នកប្រព្រឹត្តខុសហ្នឹងមកកាត់ទោស វាជាការត្រឹមត្រូវឬមិនត្រឹមត្រូវទេ បើជាយោបល់ ពូ?

ឡាយ ៈ មិនយល់ដដែលហ្នឹង។

វណ្ណៈ ៈ មិនយល់ទេ?

ឡាយ ៈ បាទ!

វណ្ណៈ ៈ អញ្ចឹងពូខ្ញុំអរគុណពូច្រើនពូណាស់។

ឡាយ ៈ បាទ!

«ចប់»